តុលាការកំពូល

សភា រដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៥៨

ចុះថ្ងៃទី០៣ខែមិថុនាឆ្នាំ១៩៩៨

សាលដីកា

លេខ : ២២០

ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ម៉ែន ស៊ុន ជាចៅក្រម

៣- លោក ទៀវ មួន ជាចៅក្រម រាយការណ៍

៤- លោក ស៊ុន ឌឹម ជាចៅក្រម

៥- លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ី សុផុន

តំណាងមហាអយ្យការ

លោក ម៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១៥១ ចុះថ្ងៃទី០៨ខែមេសាឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០២ ចុះថ្ងៃទី០៨ ខែមករាឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សួន គីមពេង ភេទស្រី អាយុ ៥៩ឆ្នាំ ជាតិ ខ្មែរ មុខរបរ ពាណិជ្ជករ ទីលំនៅភូមិ ពាលរញ្ញក ២ ឃុំ ផ្ទះព្រៃ ស្រុក សំពៅមាស ខេត្តពោធិ៍សាត់. ឪពុកឈ្មោះ លឹម ឃុន "ស" ម្តាយឈ្មោះ លី ង៉ា "ស" " លោក ទួត លុច ជាមេធាវី "

និង ចុងចម្លើយបណ្តឹងសាទុក្ខ: ១- អាជ្ញាធរខេត្តពោធិ៍សាត់ តំណាងដោយលោកម៉ក់ ទ៉ា នាយរងខុទ្ទកាល័យសាលាខេត្ត ពោធិ៍សាត់ ។

២- ចន្ទី សំណាង ភេទប្រុស អាយុ ៥៩ ឆ្នាំ ជាតិ ខ្មែរ មុខរបរ មន្ត្រី ខេត្តពោធិ៍សាត់ ទីលំនៅភូមិពាលរញ្ញក១ ឃុំ ផ្ទះព្រៃ ស្រុក សំពៅមាស ខេត្ត ពោធិ៍សាត់.ឪពុកឈ្មោះចន្ទី ម៉ុំ "ស" ម្តាយឈ្មោះពេជ្រ ពុំ "ស" " លោក ផា ផេង ជាមេធាវី"

កម្មវត្ថុបណ្តឹង: - ប្តឹងសុំមោឃភាពកិច្ចសន្យា ចុះថ្ងៃទី១៨.០១.១៩៩៦ .

- ប្តឹងទារប្រាក់ផលប្រយោជន៍ខាតចំនួន៥២០៣៧៣០ ដុល្លាអាមេរិក

ជម្ងឺចិត្ត ៦០.១០០ ដុល្លាអាមេរិក .

- ប្តឹងសុំដោះស្រាយវិវាទកិច្ចសន្យា

បានឃើញបណ្តឹងសាទុក្ខលេខ ៧៤ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៨ របស់អ្នកស្រី សួន គីមពេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ក្រោយជំរុចនីងសេចក្តីសំរេចរាំងខ្ទប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៨ ចុះថ្ងៃទី ០៣ ខែ មិថុនាឆ្នាំ ១៩៥៨ របស់តុលាការកំពូល ។

**រឿងទី ១ :**

**កម្មវត្ថុបណ្ដឹង** : ប្ដឹងសុំដោះស្រាយវិវាទកិច្ចសន្យា .

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ២៦ខែមិថុនាឆ្នាំ១៩៥៦ លោក ចន្ទ័ សំណាង ប្ដឹងសុំទទួលការខុសត្រូវក្នុងការដកប្រាក់ចំនួន ៥៥២.០០០ដុល្លាអាមេរិក ពីអ្នកស្រី សួន គឹមហេង ដោយអាងហេតុថា: លោកបានដាក់ទុនដួលទីតាំងផ្សារថ្មីពោធិ៍សាត់ ដែលមានទឹកប្រាក់ដើមរបស់លោកចំនួន ២៣៤.០០០ដុល្លា ប្រាក់ដើមរបស់លោកធា ហួយ ចំនួន ២៨៨.០០០ដុល្លា ប្រាក់ដើមរបស់លោក គង់ ស៊ីថុន ចំនួន ៨.០០០ដុល្លា និង ប្រាក់ដើមរបស់អ្នកស្រី ជួន វណ្ណា ចំនួន ២៥.០០០ដុល្លា ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៩ ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៥៧ របស់តុលាការខេត្ត ពោធិ៍សាត់ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ២៦.០៦.៥៦ របស់ឈ្មោះ ចន្ទ័ សំណាង ជាដើមបណ្ដឹងទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ប្រគល់តួនាទីដឹកនាំក្រុមហ៊ុនវិនិយោគដួលទីតាំងផ្សារថ្មីខេត្តពោធិ៍សាត់ អោយទៅឈ្មោះ ចន្ទ័ សំណាង ជានាយកចាត់ការទូទៅក្នុងក្រុមហ៊ុនទាំងមូលតាងនាមជាភាគី " ១ " ជាដៃគូដាក់ទុនវិនិយោគដួលទីតាំងផ្សារថ្មីខេត្ត ពោធិ៍សាត់ ។

- ប្រគល់តួនាទីដល់នាង សួន គឹមហេង ជានាយិការង " ជាភាគី ២ " ក្នុងនាមនីតិបុគ្គលទទួលបន្ទុកការងាររដ្ឋបាលនិងជាជួយរាជីវកម្មទំនាក់ទំនងជាមួយអាជីវករម្រាវជ្រាវនៅខ្លួនក្នុង និង ក្រៅ ។

- រាល់បញ្ហាធំៗ លោកនាយកចាត់ការទូទៅត្រូវកោះប្រជុំសមាជិកក្នុងក្រុមហ៊ុនដើម្បីសំរេចយោបល់ភាគច្រើន ។

៣- បញ្ចូលនាង លី សៀន ជាសមាជិកក្រុមហ៊ុនដែលមានទុន ៦៣.០០០ដុល្លាអាមេរិក ស្មើនឹង ១០ភាគរយ ក្នុងថិរវេលា ២០ឆ្នាំ ។

៤- ឈ្មោះ ចន្ទ័ សំណាង ជាតំណាងដៃគូដាក់ទុនមានឈ្មោះ ធា ហួយ ឈ្មោះ គង់ ស៊ីថុន និង ឈ្មោះនាង ជួន វណ្ណា ដកប្រាក់ដើម ចំនួន :

- ឈ្មោះ ធា ហួយ ចំនួន ២៨៨.០០០ដុល្លាអាមេរិក

- ឈ្មោះ ចន្ទ័ សំណាង ចំនួន ២៦៧.០០០ដុល្លាអាមេរិក គ្រប់ចំនួនខាងលើត្រូវបញ្ឈប់ការដកប្រាក់ ចាប់ពីពេលដែលដកប្រាក់ដើមអស់ឈ្មោះ ចន្ទ័ សំណាង មានសិទ្ធិទទួលកំរៃ ៥ភាគរយលើថ្លៃសរុបទុនរបស់ខេត្ត កំណត់ ៦៣០.០០០ដុល្លា បន្តរហូតដល់ផុតអាណត្តិដួលទីតាំងផ្សារ ។

៥- ក្រុមហ៊ុនទាំងមូលត្រូវដក១០ភាគរយលើតំលៃសរុបដែលខេត្តកំណត់បង់ចូលធនាគារជាកំរៃគុណប្រយោជន៍របស់ខេត្តទៀតរាល់១៥ថ្ងៃម្ដងរហូតដល់គ្រប់ចំនួន ១០០ភាគរយ ចាប់ពីពេលប្រកាសសាលក្រមនេះតទៅ ។

៦- នាង សួន គីមទេង ជាភាគី " ១ " ត្រូវមានកាតព្វកិច្ចជាមួយភាគី " ក " តាមកិច្ចសន្យាជួលទីតាំងផ្សារទាំងស្រុង នាង សួន គីមទេង ក៏ត្រូវមានកាតព្វកិច្ចផងដែរជាមួយជនដែលមានការពាក់ព័ន្ធពីបញ្ហាវិនិយោគសាងសង់សំណង់ផ្សារថ្មីពោធិ៍សាត់ ។

៧- ប្រាក់កំរៃដែលប្រមូលបានពីអាជីវករជួលតូបក្នុង និង ក្រៅត្រូវបង់ចូលធនាគារខេត្តពោធិ៍សាត់ ជាកំរិត ។

៨- អាជ្ញាធរខេត្តពោធិ៍សាត់ជាម្ចាស់ទីតាំង និង ជាភាគី " ក " ត្រូវលើកការអនុវត្ត និង ទទួលស្គាល់សមាជិកក្រុមហ៊ុនវិនិយោគជួលទីតាំងផ្សារថ្មីខេត្តពោធិ៍សាត់ ដែលមានសមាសភាពក្នុងក្រុមភាគី " ១ " ដែលមាននាង សួន គីមទេង ជានីតិបុគ្គល តែដោយឡែកឈ្មោះ ចន្ទី សំណាង តំណាងអោយដៃគូដាក់ទុនទាំងអស់ខាងលើនៅពេលដែលដកប្រាក់ដើមបង់ ១០០ភាគរយ ត្រូវប្រគល់សិទ្ធិ " នាយកចាត់ការទូទៅ " អោយទៅនាង សួន គីមទេង វិញតាមការព្រមព្រៀង ។

៩- អោយសមាជិកក្រុមហ៊ុនទាំងមូលដកភាគហ៊ុនដែលប្រមូលបានពីអាជីវករជួលតូបតាមសមាមាត្រ នៃភាគហ៊ុនរយៈពេល ១៥ថ្ងៃម្តង :

អ្នកដែលត្រូវបានទទួលតាមសមាមាត្រ នៃភាគហ៊ុនដូចខាងក្រោម :-

- ឈ្មោះ ធា ហ៊ួយ : ២៨៨.០០០ គុណ ១០០ / ៦៣០.០០០ : ៤៥ភាគរយ
- ឈ្មោះ ចន្ទី សំណាង: ២៦៧.០០០ គុណ ១០០ / ៦៣០.០០០ : ៤២ភាគរយ
- ឈ្មោះ នាងសុវ សេរីន: ៦៣.០០០ គុណ ១០០ / ៦៣០.០០០ : ១០ភាគរយ
- ឈ្មោះ នាងសួនគីមទេង ១២.០០០ គុណ ១០០ / ៦៣០.០០០ : ៣ភាគរយ

ក្នុងនេះដកពីឈ្មោះ ធា ហ៊ួយ ចំនួន ០,៧១ភាគរយ

ដកពីឈ្មោះ ចន្ទី សំណាង ចំនួន ០,៣៨ភាគរយ បញ្ចូលទៅអោយនាងសួនគីមទេង។

- សមាជិកក្រុមហ៊ុនទាំងអស់មានសិទ្ធិដកប្រាក់នេះចាប់ពីថ្ងៃ ដែលប្រកាសសាលក្រមនេះតទៅ ។

១០- ការចំណាយផ្សេងៗ ក្រៅពីការងាររដ្ឋបាល របស់ក្រុមហ៊ុន ត្រូវចំណាយប្រាក់ផ្ទាល់រៀងៗខ្លួន ។

- ឈ្មោះ ចន្ទី សំណាង ជានាយកចាត់ការទូទៅក្នុងក្រុមហ៊ុន ត្រូវកសាងបទបញ្ញាផ្ទៃក្នុងក្រុមហ៊ុនមួយ ស្តីពីតួនាទី ភារកិច្ច នៃសមាជិកក្រុមហ៊ុន និង របៀបរបបការងាររដ្ឋបាលរហូតដល់កសាងលក្ខន្តិកៈថ្មីបាន ។

- នាយកចាត់ការទូទៅត្រូវមានភារកិច្ចធ្វើរបាយការណ៍រៀងរាល់ខែជូនភាគី "ក" ដែលជាអាជ្ញាធរដែនដីខេត្តពោធិ៍សាត់ ។

- ក្នុងករណីភាគីណាមិនគោរព និង អនុវត្តតាម ឬ បង្កការរាំងស្ទះដល់ការប្រមូល

ប្រាក់ថ្លៃឈ្នួលតូចពីភាជីវករត្រូវរាប់ទំហំផលខាតតាមវិធានការរដ្ឋបាល តែក្នុងករណីធ្ងន់ធ្ងរដែលប៉ះពាល់ដល់ផលប្រយោជន៍ក្រុមហ៊ុន និង ផលប្រយោជន៍របស់អាជ្ញាធរខេត្ត និង ធ្វើអោយខូចរបៀបរៀបរយឈ្លានពានសង្គម ត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា: ១២៥ ,១៣៦ ,១៣៧ និង ១៤០ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី និង មាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ កញ្ញា ១៩៩២ ។

- ប្រាក់ប្រដាប់ក្តីត្រូវរឹបអូសដាក់ជាសម្បត្តិរដ្ឋ ។

- បង្គាប់អោយនាង សួន គឹមពេង បង់ពន្ធលេខាធិការដ្ឋានជូនរដ្ឋស្មើនឹង ចួយពាន់ " ១០០០ " ដុល្លារអាមេរិក ដោយដាក់ជាប្រយោជន៍ថវិការដ្ឋ ចំនួន ៨០ភាគរយ និង ដាក់ចូលថវិកាប្រាក់ក្រមប្រាបញ្ញើទូទាំងប្រទេស ២០ភាគរយ ពេលសាលក្រមនេះចូលជាស្ថាពរ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៣.០២.៩៣ ។

- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍ ៦០ ថ្ងៃ តាមច្បាប់គិតពីថ្ងៃកាត់សេចក្តីនេះតទៅ ។

បើភាគីណាមួយមិនសុខចិត្តត្រូវប្តឹងទៅប្តឹងឧទ្ធរណ៍ និង សាលក្រមនេះនៅមន្ទីរក្រមប្រាបញ្ញើតាមកំណត់ច្បាប់ខាងលើ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៨ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៧ របស់ឈ្មោះ ចន្ទី សំណាង ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ១៩ ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តពោធិ៍សាត់ ត្រង់ចំណុច :

- វាក្យខណ្ឌទី ២ " នាយិការង " សុំជំទាស់
- សុំប្តឹងទាមទារជម្ងឺចិត្ត ចំនួន ៣០.០០០ដុល្លារ " បីម៉ឺនដុល្លារអាមេរិក "
- សុំប្តឹងទាមទារលោហិតួយដួសជុលការទាំងស្រុះ ការធ្វើអាជីវកម្ម សេវាកម្ម ចំនួន ១០០.០០០ដុល្លារ " ដប់ម៉ឺនដុល្លារអាមេរិក "។
- សុំជំទាស់ការដកភាគហ៊ុនរបស់ខ្លួន ០ ,៣៨ភាគរយ និង លោក ឆា ឃួយ០ ,៧១ភាគរយ បន្ថែមអោយអ្នកស្រី សួន គឹម ពេង ។
- សុំពិនិត្យករឿងក្នុងពាក្យបណ្តឹងលេខ០៨១ជ.ព.ពប ចុះថ្ងៃទី ២៨.០៣.៩៧ ដែលខ្លួនបានដាក់ជូនតុលាការនាពេលជំនុំជំរះក្តី ។
- សុំតម្កល់ទុកថ្លៃឈ្នួលដីកាសំរេចតាមសទ្ធផលសះជាលេខ ១៣៦ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់តុលាការខេត្តពោធិ៍សាត់ ទុកជាបានការទាំងស្រុង

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៧ របស់អ្នកស្រី សួន គឹមពេង ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ១៩ ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៧ របស់តុលាការខេត្ត ពោធិ៍សាត់ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

រឿងទី ២ :

កម្មវត្ថុបណ្ដឹង :- ប្ដឹងសុំមោឃភាពកិច្ចសន្យា ចុះថ្ងៃទី ១៨.០១.១៩៨៦

- ប្ដឹងទារប្រាក់ផលប្រយោជន៍ខេត្ត ចំនួន៥២៣៧,៣០ ដុល្លារអាមេរិក

ជម្ងឺចិត្ត ៦០.០០០ ដុល្លារអាមេរិក .

ពាក្យបណ្ដឹង ចុះថ្ងៃទី ១២.៥.៨៧ លោក ឈុន សុង តំណាងអោយអាជ្ញាធរខេត្តពោធិសាត់ ប្ដឹងសុំមោឃភាពកិច្ចសន្យា ចុះថ្ងៃទី ១៨.០១.៨៦ រវាងអាជ្ញាធរខេត្តពោធិសាត់ និងអ្នកស្រី សួន គីមហេង ស្ដីពីវិនិយោគជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់ ដោយអាងហេតុថា: អ្នកស្រីសួន គីមហេង ដែលជាភាគី " ខ " នៃកិច្ចសន្យាពុំបានគោរពតាមកិច្ចសន្យាខាងលើ ហើយសុំបដិសេធឈប់ទទួលស្គាល់អ្នកស្រី សួន គីមហេង ជាភាគី " ខ " នៃកិច្ចសន្យាសុំអោយអ្នកស្រី សងកម្រៃផលប្រយោជន៍ខេត្តចំនួន៥២៣៧,៣០ ដុល្លារអាមេរិក ។

សងសោហ៊ុយជួសជុលការខាតបង់ប្រយោជន៍ និង ជម្ងឺចិត្ត ៦០.០០០ ដុល្លារអាមេរិក និង សុំរឹបអូសទ្រព្យសម្បត្តិដែលអ្នកស្រី សួន គីមហេង មាន និង ដាក់គុកបង្ខំដល់រូបកាយ ក្នុងករណីមិនគោរព និង អនុវត្តតាមការសំរេចរបស់តុលាការ ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ៨.៧.៨៧ លោក ធា ហ៊ួយ បានសុំចូលជាតតិយជនក្នុងរឿងក្ដីនេះ ដោយអាងហេតុថា ក្នុងការជួលទីតាំងផ្សារថ្មីពោធិសាត់ លោកបានចូលភាគហ៊ុនចំនួន២៨៨.០០០ ដុល្លារអាមេរិក ស្មើនឹង ៤៨,៧១ ភាគរយ នៃដើមទុនសរុប ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ៨.៧.៨៧ លោក ចន្ទី សំណាង បានសុំចូលជាតតិយជនក្នុងរឿងក្ដីនេះដែរ ដោយអាងហេតុថា ក្នុងការជួលទីតាំងផ្សារថ្មីពោធិសាត់នេះ លោកបានបញ្ចូលភាគហ៊ុនចំនួន ២៦៧.០០០ ដុល្លារអាមេរិកស្មើនឹង ៤២,៣៨ ភាគរយនៃដើមទុន ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ៨.៧.៨៧ លោក គង់ ស៊ីថុន បានសុំចូលជាតតិយជនក្នុងរឿងក្ដីនេះដែរ ដោយអាងហេតុថា ក្នុងការជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់នេះ លោកបានបញ្ចូលភាគទុនចំនួន ៨០០០ ដុល្លារអាមេរិក ក្នុងភាគទុនរបស់លោក ចន្ទី សំណាង ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ៨.៧.៨៧ អ្នកស្រី ដួន រដ្ឋា បានសុំចូលជាតតិយជនក្នុងរឿងក្ដីនេះដែរ ដោយអាងហេតុថា: ក្នុងការជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់នេះអ្នកស្រី បានចូលភាគទុនចំនួន ២៥.០០០ ដុល្លារអាមេរិក ក្នុងភាគទុនលោក ចន្ទី សំណាង ដែរ ។

បានឃើញដីកាសំរេចលេខ ២៣២, ២៣៣, ២៣៤, និង ២៣៥ ចុះថ្ងៃទី២៣.៨.៨៧ របស់តុលាការខេត្តពោធិសាត់ ដែលសំរេចបញ្ចូលលោកចន្ទី សំណាង, លោក ធា ហ៊ួយ, លោកគង់ ស៊ីថុន និង អ្នកស្រី ដួន រដ្ឋា ចូលជាតតិយជនក្នុងរឿងក្ដីនេះខាងដើមហោង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៧៥ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧របស់ តុលាការខេត្ត ពោធិសាត់ សំរេចចំពោះមុខដើមចោទ កំបាំងមុខចុងចោទ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ១២ ឧសភា ១៩៩៧ របស់ឈ្មោះ ឈុន សុង ប្រធានមន្ទីរផែនការខេត្តពោធិសាត់ តំណាងភាគី " ក " ជានីតិបុគ្គល " ដើមចោទ " ប្តឹងសុំមោឃភាពកិច្ចសន្យា ចុះថ្ងៃទី១៨.១.៩៦ ស្តីពីការវិនិយោគរួមទីតាំងផ្សារថ្មីពោធិសាត់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- មោឃភាពកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ ស្តីពីការវិនិយោគរួមទីតាំងផ្សារថ្មីខេត្តពោធិសាត់ ដែលមានឈ្មោះ សួន គីមហេង " ចុងចោទ "ភាគី "ខ " ជានីតិបុគ្គល អោយចេញពីភាគីហត្ថលេខី ចាប់តាំងពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៣- រក្សាសិទ្ធិ និង ទទួលស្គាល់ :-

- ឈ្មោះ ធា ប៊ុយ មានភាគហ៊ុន ចំនួន ២៧៨.០០០ដុល្លាអាមេរិក
- ឈ្មោះ ច័ន្ទ ណំរាង មានភាគហ៊ុន ចំនួន ២៦៧.០០០ដុល្លាអាមេរិក
- ឈ្មោះ ស សឿន មានភាគហ៊ុន ចំនួន ៦៣.០០០ដុល្លាអាមេរិក

ក្នុងហ៊ុនវិនិយោគរួមទីតាំងផ្សារថ្មីពោធិសាត់ចាប់តាំងពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៤.ក- អោយចុងចោទឈ្មោះ សួន គីមហេង បង់ប្រាក់គុណប្រយោជន៍ខេត្ត ចំនួន ៥.២៣៧,៣០ដុល្លាអាមេរិក ជាប្រយោជន៍ថវិការដ្ឋ ចាប់តាំងពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

ខ- អោយចុងចោទឈ្មោះ សួន គីមហេង បង់ប្រាក់ជួសជុលការខាតបង់ និង ជម្ងឺចិត្ត ដល់រាជ្ញាធរខេត្តពោធិសាត់ ចំនួន ៣០.០០០ដុល្លាអាមេរិក លើសពីនេះលើកចោល ជាប្រយោជន៍ ថវិការដ្ឋ ។

ករណីចុងចោទរឹងរូសមិនព្រមបង់ប្រាក់តាមឃ្លា " ក " និង " ខ " ត្រូវដាក់គុកបង្ខំរូបកាយតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រម ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី ២ ឧសភា ១៩៩២ ។

៥- អោយចុងចោទ បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល សរុប៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទ បង់ទុករួចហើយ ហើយចុងចោទត្រូវប្រគល់អោយដើមចោទ វិញ និង អោយបង់ពន្ធសមាមាត្រ ១ភាគរយស្មើនឹងប្រាក់ដុល្លាអាមេរិក ៣៥២ ៣៧៣ ប្រាក់នេះដាក់ជាថវិការដ្ឋ ៨០ភាគរយ និង ២០ភាគរយទៀត ជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ៗតាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ។

៦- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចោទ ទុករយៈពេលប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

៣ៗ.

បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់អ្នកស្រី សួន គឹមហេង ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ៧៤ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៨៩ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់ តុលាការខេត្ត ពោធិសាត់ សំរេចចំពោះមុខដើមចោទ និង តតិយជនកំបាំងមុខចុងចម្លើយលើកទី ២ ទុក ជាចំពោះមុខ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- បដិសេធសាលក្រមកំបាំងមុខលេខ ៧៤ ចុះថ្ងៃទី ៩.១១.៩៧ របស់តុលាការខេត្ត ពោធិសាត់ ។

២- ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ឈុន សុង ប្រធានមន្ទីរផែនការខេត្តពោធិសាត់ តំណាងភាគី " ក " ប្តឹងសុំមោឃភាពមិនទទួលស្គាល់ហត្ថលេខាឈ្មោះ សួន គឹមហេង ជាភាគី " ខ " ចេញ ពីកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ ស្តីពីការវិនិយោគជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់ទុកជាត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ ។

៣- ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ចន្ទី សំណាង នាយកចាត់ការទូទៅផ្សារថ្មីខេត្ត ពោធិសាត់ ជាតតិយជនបញ្ចូលក្នុងរឿងរដ្ឋប្បវេណីលេខ ១០៨ ចុះថ្ងៃទី ៨.៩.៩៧ ទុកជាត្រឹមត្រូវតាម ទំរង់ និង គតិច្បាប់ ។

៤- រក្សាកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ ស្តីពីការទិញ លក់ភាគទុនវិនិយោគ សាងសង់ផ្សារថ្មីខេត្ត ពោធិសាត់ ទុកជាបានការទាំងមូល ។

៥-ក. ទទួលសំណូមពររបស់ដើមចោទ នាពេលសវនាការរបស់ឈ្មោះឈុន សុង សុំ រក្សានូវកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ អោយនៅដដែល តែសុំអោយលុបឈ្មោះ សួន គឹមហេង ចេញ ពីកិច្ចសន្យានេះទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ- ទទួលសំណូមពររបស់ឈ្មោះ ចន្ទី សំណាង នាយកចាត់ការទូទៅសុំទាមទារ ប្រាក់ពីឈ្មោះ សួន គឹមហេង និង ឈ្មោះ ផាន់ វ៉ារិន ជាប្តីនូវប្រាក់ជំពាក់ក្រុមហ៊ុន ចំនួន ៧៤.៧២០$៣១ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៦- រក្សាកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ ស្តីពីការវិនិយោគជួលទីតាំងផ្សារថ្មី ខេត្តពោធិសាត់ អោយនៅដដែលតែបដិសេធលែងទទួលស្គាល់ឈ្មោះ សួន គឹមហេង ភាគី " ខ " ជាភាគី ហត្ថលេខី ចេញពីកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ តាមមាត្រា ១០៧ ,១០៨ នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និង ទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨.១០.៨៨ ហើយទទួលស្គាល់ឈ្មោះ ចន្ទី សំណាង នាយក ចាត់ការទូទៅតាមសាលក្រមលេខ ១៩ ចុះថ្ងៃទី ២៣.៣.៩៧ ជាតំណាងអោយក្រុមហ៊ុនវិនិយោគជួលទីតាំង ផ្សារថ្មីខេត្តពោធិសាត់ចាប់តាំងពីថ្ងៃនេះតទៅ អោយបន្តនូវសកម្មភាពក្នុងក្រុមហ៊ុន ។

៧- រក្សាសិទ្ធិ និង ទទួលស្គាល់ភាគទុនរបស់ឈ្មោះ ធា ប៊ួយ ២៨៨.០០០ដុល្លា , ឈ្មោះ ចន្ទី សំណាង មានភាគទុន២០៧.០០០ដុល្លា ,ឈ្មោះ ស សឿន មានភាគទុន៦៣.០០០ដុល្លា ក្នុង ទុនវិនិយោគជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់ ។

៨ - បង្គាប់អោយឈ្មោះ លួន គឹមហេង បង់ប្រាក់សំណងប្រយោជន៍ខេត្តពោធិសាត់ ចំនួន ៥២៣៧៥/៣០ និង ជំងឺចិត្ត ចំនួន ៣០.០០០ដុល្លា អោយទៅភាគី " ក " ទុកជាប្រយោជន៍ថវិការដ្ឋ ចាប់ពីពេលសាលក្រមចូលជាស្ថាពរ ។

៩ - បង្គាប់អោយឈ្មោះ លួន គឹមហេង " ចុងចម្លើយ " ទូទាត់បំណុលវិញភាគទុនផ្សារថ្មី ពោធិសាត់ ពីសហគ្រាសឃ្លាំងអង្ករជាតិតាមកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៨៦ ទៅអោយសហគ្រាសឃ្លាំងអង្ករជាតិ ជាភាគី " ក " ជាអ្នកឈរក់ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

១០ - បង្គាប់អោយឈ្មោះ លួន គឹមហេង និង ឈ្មោះ ផាន់ រ៉ារិន ជាប្តីសងប្រាក់ជំពាក់ក្រុមហ៊ុន ៧៤.៣២០ ៣១ដុល្លា និង ប្រាក់ខាតបង់១០៥.១១០ដុល្លា អោយទៅឈ្មោះ ចន្ទី សំណាង តំណាងក្រុមហ៊ុន ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។ ករណីរឹងរូសមិនព្រមទូទាត់ប្រាក់គ្រប់ចំនួនតាមចំណុច ៨ ,៩ ,១០ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងយកទៅទូទាត់បំណុល ករណីរឹងទទឹងត្រូវដាក់គុកបង្ខំរូបកាយតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី២ ឧសភា ១៩៧២ ។

១១ - អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១៨០០រៀល គុណ ២ ស្មើ ៣៦០០រៀល រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ២០០រៀល គុណ ២ ស្មើ ៤០០រៀល រង្វាន់អ្នកប្រគល់ដីការកោះនិង ការស៊ើបអង្កេត ៥០០០រៀល គុណ ២ ស្មើ ១០.០០០រៀល សរុប ១៤.០០០រៀល ប្រាក់នេះបានកាត់មកពីប្រាក់ ១៤.០០០រៀល ដែលដើមចោទ បង់ទុករួចហើយ បើឈ្នះឧទ្ធរណ៍ប្រគល់អោយដើមចោទ វិញ និង អោយចុងចម្លើយបង់ពន្ធសមាមាត្រ ១ភាគរយ នៃប្រាក់ជំពាក់ ប្រាក់នេះដាក់ជាថវិការដ្ឋ ៨០ភាគរយ និង ២០ភាគរយទៀតជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ៨កុម្ភៈ ១៩៨៣ ។

១២ - សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ និង តតិយជនកំបាំងមុខចុងចម្លើយលើកទីពីរ ទុកជាចំពោះមុខបើកផ្លូវឧទ្ធរណ៍ ២ខែ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៦ ចុះថ្ងៃទី ១៥.១២.៨៧ របស់អ្នកស្រី លួន គឹមហេង ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ៨៨ ចុះថ្ងៃទី ១១.១២.៨៧ របស់តុលាការខេត្តពោធិសាត់លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ ២០ ចុះថ្ងៃទី ០៦.៤.៨៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

- ចាត់របៀបដោយៈ បញ្ចូលសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ២៦៣ ចុះថ្ងៃទី០៥.៥.១៩៨៧ របស់សាលាឧទ្ធរណ៍ ទៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០២ ចុះថ្ងៃទី ០៨.០១.១៩៨៨ របស់សាលាឧទ្ធរណ៍ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ០៨.៤.៨៨ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២.៥.៨៧ របស់ឈ្មោះលួន គឹមហេង និង បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០១.៤.៨៧របស់ឈ្មោះ ចន្ទី សំណាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥.១២.៨៧ របស់ឈ្មោះ សួន គឹមហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

៣ - បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៥ ចុះថ្ងៃទី ១៩.៣.១៩៨៧ របស់តុលាការខេត្តពោធិសាត់ ចោលជាអាសារបង់ ។

៤ - តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨៨ ចុះថ្ងៃទី ១១.១២.១៩៨៧ របស់តុលាការខេត្តពោធិសាត់ ទុកជាបានការពេញទាំងមូល ។

៥ - សំរេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ចំនួន ២៦.០០០ រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ៥១០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៩០០ រៀល ចំណាយក្នុងការប្រេសដីកាកោះ ១០.០០០ រៀល និង អាជ្ញាធរតុលាការ ១០.០០០ រៀល សរុប ២៦.០០០ រៀល ។

៦ - សាលដីកានេះជំនុំជំរះនៅថ្ងៃទី ០៦.៤.១៩៨៨ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៨.៤.១៩៨៨ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៨៨ របស់អ្នកស្រី សួន គឹមហេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៨៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងស្រុង ។

បានឃើញសារណា ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៨៨ របស់អ្នកស្រី សួន គឹមហេង

បានឃើញសារណាតប ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៨៨ របស់លោក ចន្ទី ឈំណាង

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :-

ក្រោយពីបានពិនិត្យលើសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីឯកនេះ មានការខុសឆ្គងលើគតិច្បាប់ ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះទេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ផាន់ វ៉ារិន " តំណាងអោយអ្នកស្រី សួន គឹមហេង " ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: បានជាខ្លួនប្តឹងសាទុក្ខនឹងសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ៨.៤.៨៨ របស់សាលាឧទ្ធរណ៍ ព្រោះថាការកាត់សេចក្តីរបស់សាលាឧទ្ធរណ៍ គឺមានការភន្តច្រឡំ ដោយហេតុថា អ្នកស្រី សួន គឹមហេង ជាអ្នកជាប់កិច្ចសន្យាជាមួយអាជ្ញាធរខេត្តរយៈពេល ២០ឆ្នាំ ។ ដែលជាអ្នកម្ចាស់ទីផ្សារ ទៅជាកូនបំណុល ហើយថា ជាអ្នកកម្រៃធន់ទៅវិញ ។

បានស្តាប់ចម្លើយរបស់លោក ម៉ក់ រ៉ា ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: ក្នុងនាមអាជ្ញាធរខេត្ត ខ្លួនសុំដកពាក្យបណ្តឹងទាំងអស់របស់លោក ឈុន ស៊ុង

ចោលទាំងស្រុង និង សុំទុក្រាកិច្ចសន្យា ចុះថ្ងៃទី ១៨.០១.១៩៨៦ ជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់ តទៅទៀត ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ច័ន្ទ សំណាង ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយពន្យល់ថា៖ ក្នុងការវិនិយោគជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់នេះ អ្នកស្រីសួនគីមហេង ត្រូវខ្វែងរកប្រភពទុនអោយបានចំនួន ៤៦៤.៧៧០ដុល្លា ដោយបញ្ចូលនិងប្រាក់ពុករលួយដល់ខេត្ត ចំនួន ៧៤.៧៤០ដុល្លា ដើម្បីទិញភាគទុនពីសហគ្រាសឈើអន្តរជាតិ ដែលជាភាគីវិនិយោគសាងសង់ផ្សារថ្មីខេត្តពោធិសាត់ ។ ក្នុងរបាយការណ៍ជំរះបញ្ជីភាគទុន និង បំណុល ចុះថ្ងៃទី ១២.០១.៨៦ សហគ្រាសឈើអន្តរជាតិ នៅជំពាក់អ្នកស្រី សួន គីមហេង ចំនួន ៥៧.០០០ដុល្លា , លោក ធា ឆួយ ចំនួន១៦៨.៥២២ដុល្លាអាមេរិក លោក ច័ន្ទ សំណាង ៧០.០០០ដុល្លា និង លោក គង់ ស៊ីថុន ចំនួន ៨០០០ដុល្លាសរុប៣០៣.៥២២ដុល្លាអាមេរិក បរិមាណទឹកប្រាក់ចំនួន ៣០៣៥២២ដុល្លានេះអ្នកស្រី សួន គីមហេង បានខ្ចីពីម្ចាស់ភាគទុន និង ម្ចាស់បំណុល សំរាប់ធ្វើការកាត់កងជាមួយថ្លៃទិញភាគទុនរបស់សហគ្រាសឈើអន្តរជាតិ ។ នៅខ្វះប្រាក់ចំនួន១៦១.១៧៨ដុល្លាទៀត អ្នកស្រី សួន គីមហេង ភាគី " ខ " ក្នុងនាមជារូបវន្តបុគ្គល បានធ្វើកិច្ចសន្យាចុះថ្ងៃទី១៦.០១.៨៦ កាន់ដីឡូត៍លេខ ៣៦៧ ក្រុមទី ១៥ ភូមិព្រែកតាគង់ សង្កាត់ ចាក់អង្រែលើ ខណ្ឌ មានជ័យ ក្រុងភ្នំពេញ ជូនភាគីសហគ្រាសឈើអន្តរជាតិ ជាភាគី " ក " ។ ក្នុងកំណត់ហេតុ ចុះថ្ងៃទី ២៣.០១.៨៦ របស់មមូលភាព ក្រុមហ៊ុនវិនិយោគជួលទីតាំងផ្សារថ្មីខេត្តពោធិសាត់ បានចាត់តាំងរូបខ្លួន ច័ន្ទ សំណាង ជានាយកចាត់ការទូទៅ និង ទទួលបន្ទុកការងារគណនេយ្យ ហិរញ្ញវត្ថុ និង រដ្ឋបាល ។ចំណែកអ្នកស្រី សួន គីមហេង ជាប្រធានត្រួតពិនិត្យផ្សារ ទទួលបន្ទុកភារកិច្ច រៀបចំផ្សារ ។ ដោយអ្នកស្រី សួន គីមហេង និង ប្តី ញ៉ាំនគោរព និង អនុវត្តតាមខ្លឹមសារនៃរបាយការណ៍ជំរះបញ្ជី ចុះថ្ងៃទី ១២.០១.៨៦ និង កិច្ចសន្យា ចុះថ្ងៃទី១៧.១.៨៦ ភាគទុន និង បំណុលរបស់ខ្លួន , លោក ធា ឆួយ , លោក គង់ ស៊ីថុន និង អ្នកស្រី ជួន វណ្ណា ដែលពុំទាន់មានការធានាគ្រប់គ្រាន់ នឹងអាចបណ្តាលអោយអ្នកស្រីរូបនេះ ធ្វើអោយបាត់បង់ផលប្រយោជន៍ ។

ទុនរបស់ខ្លួន រួមមានកំរៃសេវាកម្មដែលអ្នកស្រី បានផ្តល់អោយខ្លួន ដែលបានខិតខំបំពេញបែបបទ ដើម្បីជួលទីតាំងផ្សារពោធិសាត់ តាំងពីដើមរហូតដល់បានសេចក្តីសំរេចពីក្រសួងមហាផ្ទៃចំនួន១៥ភាគរយ ស្មើទុនកំណត់ ១៣០.០០០ដុល្លា ស្មើនឹង ៩៤.៥០០ដុល្លាកាត់កងភាគទុនពីសហគ្រាសឈើអន្តរជាតិ ចំនួន ៧០.០០០ដុល្លា ប្រាក់ទិញរថយន្តបណ្តាក់មួយគ្រឿង ចំនួន ២៨.៥០០ដុល្លា សណ្ឋាគារកំរៃសេវាកម្មពីសហគ្រាសឈើអន្តរជាតិ អោយអ្នកស្រី សួន គីមហេង ចំនួន ៥០០០ដុល្លា បន្ថែមទុនសំរាប់សាងសង់ថ្មី ស្តង់អាលុយមីនីញ៉ូម ចំនួន ៣៦.០០០ដុល្លា សរុបប្រាក់ទុនរបស់ខ្លួនមាន ២៣៤.០០០ដុល្លា ។

បានស្តាប់សេចក្តីសន្និដ្ឋាន របស់លោកទួត លុច ជាមេធាវីរបស់ចុងចម្លើយ និង ជាដើមបណ្តឹងសាទុក្ខបានលើកឡើងថា៖ កាលពីថ្ងៃទី ៨.១១.៨២ គណៈកម្មាធិការប្រជាជនខេត្តពោធិសាត់ បានព្រមព្រៀងគ្នាជាមួយសហគ្រាសចំរើនផលធ្វើវិនិយោគទុនសាងសង់ផ្សារថ្មីនៅ ខេត្តពោធិសាត់ តែដោយសហគ្រាសចំរើនផល ពុំបានអនុវត្តធ្វើវិនិយោគសាងសង់ផ្សារថ្មីនៅ ខេត្តពោធិសាត់នេះទេ ក៏បានផ្ទេរសិទ្ធិជូនទៅសហគ្រាសឈើអន្តរជាតិជាអ្នកអនុវត្តទៅវិញ ។តាមការផ្ទេរសិទ្ធិនេះបណ្តាលអោយសហគ្រាស

សំណង់អន្តរជាតិ បានចុះកិច្ចសន្យាធ្វើវិនិយោគទុនសាងសង់ផ្សារថ្មីនៅខេត្តពោធិសាត់ ដោយតាំងខ្លួនជាភាគី "ខ" ជាមួយនឹងគណៈកម្មាធិការប្រជាជនខេត្តពោធិសាត់ហៅថាភាគី "ក" នៅថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ខ្លឹមសារនៃកិច្ចសន្យានេះភាគី "ក" អនុញ្ញាតអោយភាគី "ខ" ធ្វើវិនិយោគទាំងស្រុងលើសំណង់ផ្សារថ្មីក្នុងខេត្តពោធិសាត់លើផ្ទៃដី ៦៣៧៣ម៉ែត្រការ៉េ ដែលត្រូវសង់តូបលក់ដូរចំនួន ៦៧២តូប ក្នុងរយៈពេល ៧ខែ ។ ចំណែកភាគី "ខ" បានវិនិយោគទុនចំនួន៧០៧.៣៨៦ដុល្លារអាមេរិក និងត្រូវលក់តូបនីមួយៗ ក្នុងតំលៃជាមធ្យម ១.២០០ដុល្លារអាមេរិក ។

សហគ្រាសសំណង់អន្តរជាតិ បានចុះកិច្ចសន្យាសហប្រតិបត្តិការរួមគ្នា ធ្វើវិនិយោគបន្តការសាងសង់ផ្សារថ្មីពោធិសាត់ ជាមួយក្រុមហ៊ុន សួន គឹមហេង ដោយតំរូវអោយក្រុមហ៊ុនសួនគឹមហេងចេញប្រាក់ចំនួន ១៦៦.០០០ដុល្លារអាមេរិក សងបំណុលចាស់ដែលសហគ្រាសសំណង់អន្តរជាតិ បានជំពាក់ថ្លៃទិញសំភារៈ និង ឈ្នួលកម្មសាងសង់ផ្សារថ្មី ហើយក្រុមហ៊ុន សួន គឹមហេង បានទទួលភាគទុន ៣០ភាគរយ ក្នុងក្រុមហ៊ុនដែលបានមកពីការលក់តូប ៦៧២តូប គិតជាដើមទុនស្មើ ២៤១.៩២០ដុល្លារអាមេរិក ។ ក្នុងនាមខ្លួនជាមេធាវីការពារអោយអ្នកស្រី សួន គឹមហេង ខ្លួនសុំអោយតុលាការ ធ្វើការបដិសេធនូវបណ្តឹងមួយចំនួនដូចតទៅ :- ១- ដីកាសំរេចតាមលទ្ធផលសះជា បានធ្វើឡើងដោយខុសនឹងសារាចរណែនាំលេខ ០៥ ចុះថ្ងៃទី ០៨.៩.៨៥ ។

២- កំណត់ហេតុសំរុះសំរួល ចុះថ្ងៃទី ២៦.៦.៩៦ ដែលបណ្តាលអោយលោក អ៊ុន សំណាង ចេញដីកាសះជាលេខ ១៣៦ ចុះថ្ងៃទី ២៧.៦.៩៦ នោះខុសនឹងមាត្រាច្បាប់នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា ចុះថ្ងៃទី ២៨.១០.១៩៨៨ត្រង់មាត្រា ៦,៧,៩,១០,១១,១២ ។

៣- អ្នកស្រី សួន គឹមហេង ត្រូវទទួលសិទ្ធិគ្រប់គ្រងផ្សារ ហើយត្រូវសងបំណុលដល់ម្ចាស់បំណុល ដោយយោងតាមមាត្រា ២៤ នៃក្រឹត្យច្បាប់លេខ ៣៨ និង សុំអោយតុលាការកំពូល បដិសេធចោលនូវសាលដីការបស់សាលាឧទ្ធរណ៍ ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ជា ផេង ជាមេធាវីរបស់លោក ចន្ទ សំណាង ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ បានលើកឡើងថា: ទាំងសហដិកក្រុមហ៊ុន ទាំងអាជ្ញាធរខេត្ត ទាំងសហគ្រាសសំណង់អន្តរជាតិ សុទ្ធតែបានឯកភាពតាមសេចក្តីសំរេចនៃសាលក្រមលេខ ៨៨ ចុះថ្ងៃទី ១១.១២.៩៧ របស់តុលាការខេត្តពោធិសាត់ និង សេចក្តីសំរេចនៃសាលដីកាលេខ ១៥១ ចុះថ្ងៃទី៨.០៥.៩៨ របស់សាលាឧទ្ធរណ៍ ។ ដូច្នេះការលើកឡើងរបស់លោក ផាន់ វ៉ារិន ប្តីអ្នកស្រី សួន គឹមហេង ក្នុងសារណា ចុះថ្ងៃទី ៣០.៦.៩៨ សុទ្ធតែបំភ័ន្តទាំងអស់ ។ខ្លួនសុំអោយក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេចតម្កល់សាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ០៨.៥.៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧៨ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៨ របស់អ្នកស្រី សួន គឹមហេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមលេខ ៨៨ ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់តុលាការខេត្តពោធិសាត់ ទុកជាបានការពេញទាំងស្រុង នោះជាការភន្តច្រឡំ ពីព្រោះថា តាមលិខិតចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ លោក ម៉ក់ រ៉ា ជាតំណាងថ្មីរបស់អាជ្ញាធរខេត្តពោធិសាត់ បានសុំដកពាក្យបណ្តឹង ចុះថ្ងៃទី ០៨.០១.៩៨ " ប្តឹងសុំមោឃៈភាពកិច្ចសន្យា " និងរាល់ពាក្យបណ្តឹងទាំងឡាយរបស់លោក ឈុន សុង " តំណាងអាជ្ញាធរខេត្តចាស់ " នោះមានន័យថា អាជ្ញាធរខេត្ត ដែលជាដើមចោទ ក្នុងរឿងក្តីនេះបានសុំដកពាក្យបណ្តឹងវិញហើយ ដែលជាហេតុការណ៍ សាលាឧទ្ធរណ៍ ត្រូវបំណាយរឿងក្តីនេះ ចេញពីបញ្ជីក្តី ។ ក្នុងករណីមានពាក់ព័ន្ធដល់ផលប្រយោជន៍របស់តតិយជន ឬ ដើមបណ្តឹងផ្សេងទៀត ក៏គប្បីសាលាឧទ្ធរណ៍ ញែករឿងផលប្រយោជន៍នោះ ហើយសំរេចដោយឡែកដែរ មិនត្រូវសំរេច ឬ តម្កល់អ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍ ឬ ឆន្ទៈរបស់អាជ្ញាធរខេត្ត ដែលជាដើមចោទ នោះឡើយ ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមសំរេចទទួលស្គាល់លោកចន្ទី សំណាង ជាភាគី " ១ " ហត្ថលេខី នៃកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ នោះក៏ជាការខុសឆ្គងដែរ ពីព្រោះថា កិច្ចសន្យា ចុះថ្ងៃទី ១៨.០១.៩៦ ត្រូវបានចុះហត្ថលេខា ដោយអ្នកស្រី សួន គឹមហេង ជាភាគី " ១ " ទោះក្នុងនាមជានីតិបុគ្គល ក៏ពិតមែន ប៉ុន្តែពុំមានភស្តុតាងណាមួយថា មុនពេលចុះហត្ថលេខា លើកិច្ចសន្យានេះ មានក្រុមហ៊ុនមួយ ដែលមានលោក ចន្ទី សំណាង និង អ្នកផ្សេងទៀត ជាសមាជិក នៃក្រុមហ៊ុននេះឡើយ ដូចដែលមានបញ្ជាក់ក្នុងសេចក្តីសំរេចចិត្តស្តីពីការវិនិយោគជួលទីតាំងផ្សារថ្មីខេត្ត ពោធិសាត់ ត្រង់ប្រការ ១ ដែលចែងថា " ប្រគល់សិទ្ធិអោយអ្នកស្រី សួន គឹមហេង ភាគីមួយក្នុងចំណោមភាគីវិនិយោគសាងសង់ផ្សារថ្មីខេត្តពោធិសាត់ " និង ប្រការ ៣ ដែលចែងថា " តំណាងភាគីវិនិយោគចាស់ទាំង ៣ រួមមានលោក ផាម ស៊ិនតាវ អ្នកស្រី សួន គឹមហេង និង លោក ចន្ទី សំណាង មានភារៈកិច្ចជំរះបញ្ជីទូទាត់បំណុល ... ។ " ម្យ៉ាងទៀតតាមកំណត់ហេតុ នៃសម័យប្រជុំ ចុះថ្ងៃទី ៩.០១.៩៦ រវាងអាជ្ញាធរខេត្ត និង ភាគីសហប្រតិបត្តិការសាងសង់ផ្សារថ្មីខេត្តពោធិសាត់ ត្រង់ចំណុចទី ២ អង្គប្រជុំបានសំរេចជា

គោលការណ៍ថា " ផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្មជួលតូបជំរុះ ឲ្យអ្នកស្រី លួន គឹមហេង ជាភាគីមួយក្នុងចំណោមក្រុមសហប្រតិបត្តិការ ... ។ " ដូច្នេះ ទោះបីកិច្ចសន្យា ចុះថ្ងៃទី ១៨.១.៩៦ កំណត់ថាអ្នកស្រី លួន គឹមហេង ជានីតិបុគ្គលក៏ពិតមែន ប៉ុន្តែពុំមែនតំណាងឲ្យក្រុមហ៊ុនដែលមាន លោក ចន្ទ័ សំណាង ឬ លោក ផាម ស៊ុនតារ៉ា ជាសមាជិកភាគហ៊ុនទេឡើយ ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមយល់ថា អ្នកស្រី លួន គឹមហេង ត្រូវក្បត់ក្នុងការធ្វើអាជីវកម្មនោះក៏ជាការភ័ន្តច្រឡំដែរពីព្រោះថា ក្រៅពីប្រាក់ទុន ៥៧.០០០ដុល្លាអាមេរិក អ្នកស្រី បានទូទាត់បំណុលជាផ្ទះ ៤ល្វែងក្នុងតម្លៃ ៣០០.០០០ដុល្លាអាមេរិក ជូនលោក ហា ប៊ួយ និង នីមួយតម្លៃងជូនសហគ្រាសលំហដ៏អន្តរជាតិ ប៉ុន្តែការទូទាត់នេះពុំបានសំរេចទើបបង្វិលទៅជាប្រាក់ជំពាក់ទូទាត់តាមកិច្ចសន្យាតាមកំណត់កាល នៃការប្រគល់ថ្លៃតូបទៅវិញ ។ ជាគោលការណ៍ទុន របស់ពាណិជ្ជករ ឬ ឧស្សាហកម្ម ក្រៅពីប្រាក់សុទ្ធ នៅមានទុនជាយាន និង អចលនទ្រព្យ ឬ ជាមុខទំនិញបន្ថែមទៀត ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមសំរេចទទួលស្គាល់ភាគទុនរបស់លោក ហា ប៊ួយ ចំនួន ២៨៨.០០០ដុល្លាអាមេរិក ទុនរបស់លោក ចន្ទ័ សំណាង ចំនួន ២៦៧.០០០ដុល្លាអាមេរិក និង ទុនផ្សេងៗទៀត ដោយពុំបានពិភាក្សាពីទុនទាំងនោះ ដោយបានច្បាស់លាស់នោះជាការចំពានទៅនឹងមាត្រា ៣១ មាត្រា ៥៨ និង មាត្រា ៦០ នៃក្រឹត្យ-ច្បាប់លេខ ៣៨ក្រ.ច ស្ដីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យាពីព្រោះថា ... ប្រាក់ទាំងនេះត្រូវតែទុកជាប្រាក់ជំពាក់ ហើយក្នុងប្រាក់.. ចំនួនទាំងនេះក៏មានការប្រាក់ខុសច្បាប់ ប្រាក់ សងសំណាច់ និង ប្រាក់ជម្ងឺចិត្តបន្ថែមទៀតផង ដូចមានកំណត់ក្នុងលិខិត ចុះថ្ងៃទី ៤.១១.៩៧ ដែលតុលាការខេត្តពោធិ៍សាត់ បានផ្ញើជូនសាលាឧទ្ធរណ៍ ត្រង់ចំណុចទី ៣ ។

- យល់ឃើញថា ដោយលោក ចន្ទ័ សំណាង ពុំមានសញ្ញាសម្បត្តិជាភាគី " ១ " នៃកិច្ចសន្យា ចុះថ្ងៃទី ១៨.០១.៩៦ ទេនោះដូច្នេះរាល់ការសំរេចរបស់តុលាការថ្នាក់ក្រោម ដែលតំរូវឲ្យអ្នកស្រី លួន គឹមហេង បំពេញកាតព្វកិច្ចតាមបណ្ដឹងរបស់លោក ចន្ទ័ សំណាង ក្នុងនាមជាភាគី " ១ " នោះត្រូវទុកជាមោឃៈ ដោយឯកឯង ។

- យល់ឃើញថា លោក ចន្ទ័ សំណាង ដែលពុំបានប្ដឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍នោះអស់សិទ្ធិជាដើមចោទក្នុងសំណុំរឿងលេខ ២៦៣ ចុះថ្ងៃទី ៥.៥.៩៧ ទៀតហើយ ពីព្រោះសាលដីការដ្ឋប្បវេណីលេខ ១៥១ បានសំរេចបដិសេធសាលក្រមលេខ ១៥ ចុះថ្ងៃទី ១៥.៣.៩៧ របស់តុលាការខេត្តពោធិ៍សាត់ ចោលជាអសារបង់រួចហើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងអង្គច្បាប់ ។

ហេ តុ ដូ ច្នេះ

វិនិច្ឆ័យសេចក្ដី ចំពោះមុខគូក្ដី

១_ ទទួលបណ្ដឹងសាទុក្ខលេខ ៧៨ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៨ របស់អ្នកស្រី លួន គឹមហេង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចទី ៣ នៃវិនិច្ឆ័យសេចក្ដីដែលត្រូវរក្សាទុកជាបានការ ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៨ ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៩.០០០ រៀល ដែលអ្នកស្រី លួន គឹមហេង បានបង់រួចហើយ គឺ :_

_ ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ចំនួន ៤.០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

_ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០ រៀល សរុប១៩.០០០ រៀល ហើយត្រូវបង្ខំអោយលោក ចន្ទី សំណាង សងប្រាក់ ចំនួន ១៩.០០០ រៀលនេះ ទៅអ្នកស្រីលួន គឹមហេង វិញ ។

៥_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៨ ។